ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០២-២១៨ ប.ក

# ប្រកាស
## ស្តីពី
## ការដាក់អោយអនុវត្តប្លង់គណនី សំរាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមការសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០០២ ។

## សំរេច

**ប្រការ ១.-**

ដាក់ចេញប្លង់គណនី និងកាតព្វកិច្ចបើកចំហពតិមានសំរាប់គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អោយអនុវត្តដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

**ប្រការ ២.-**

ការអនុវត្តន៍នូវប្លង់គណនីនិងកាតព្វកិច្ចបើកចំហពតិមានត្រូវចាប់ផ្តើមនៅថ្ងៃទី០១ខែមករា ឆ្នាំ២០០៣ ។

**ប្រការ ៣.-**

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងៗ រួមមានរបាយការណ៍រូបិយវត្ថុដែលត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា សំរាប់ខែមករាឆ្នាំ២០០៣ និងគ្រាបន្តបន្ទាប់ត្រូវបំពេញត្រឹមត្រូវលើមូលដ្ឋានប្លង់គណនី និងកាតព្វកិច្ចបើកចំហពតិមាន ។

**ប្រការ ៤.-**

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិបង្កើតបន្ថែម ឬលុបចោលឈ្មោះ និងលេខគណនី តាមការចាំបាច់ ។

**ប្រការ ៥.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវអនុវត្តតាមផងដែរនូវស្តង់ដារគណនេយ្យកម្ពុជា ដែលចេញដោយក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្នុងករណីដែលកាតព្វកិច្ចគណនេយ្យកំណត់ដោយធនាគារជាតិនៃកម្ពុជាមានភាពខុសគ្នាពីស្តង់ដារគណនេយ្យកម្ពុជា កាតព្វកិច្ចដែលតំរូវដោយធនាគារជាតិនៃកម្ពុជាត្រូវមានប្រសិទ្ធភាពអនុវត្ត ។

**ប្រការ ៦.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០២

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"